អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

# អង្គភាពគាំពារជនរងគ្រោះរៀបចំកិច្ចពិភាក្សាតុមូលស្តីពី ការគាំទ្រកាន់តែទូលំទូលាយដល់ជនរងគ្រោះ

ដោយមានកិច្ចសហការជាមួយ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ សមាគម ការពារសិទ្ធិមនុស្សកម្ពុជា(CHRAC) អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានរៀបចំកិច្ចពិភាក្សាតុមូលមួយស្តីពីទម្រង់នៃការគាំទ្រក្រៅដំណើរការតុលាការកាន់តែទូលំទូលាយដល់ជនរងគ្រោះ ជាមួយនឹងការចូលរួមពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គការសង្គមស៊ីវិល ស្ថាប័នសិក្សា និងបុគ្គលិកតុលាការ នៅថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១០កន្លងទៅថ្មីៗនេះ។

ដើម្បីផ្តល់ជូនអ្នកចូលរួមនូវទិដ្ឋភាពផ្នែកក្របខណ្ឌការងារកាន់តែច្បាស់មួយ អំពីការពិពណ៌នាដោយផ្ទាល់របស់ជនរងគ្រោះ ពាក់ព័ន្ធនឹងតម្រូវការ និងផលប្រយោជន៍របស់ពួកគាត់ អង្គភាពគាំពារជនរងគ្រោះបានធ្វើបទបង្ហាញស្តីពីលទ្ធផលនៃការវិភាគដ៏ទូលំទូលាយមួយនៃចំណូលចិត្តចង់បានទាក់ទងនឹងសំណង ដូចមានពណ៌នាដោយជនរងគ្រោះពីរបបខ្មែរក្រហមក្នុងទម្រង់បែបបទព័ត៌មានជនរងគ្រោះ ដែលពួកគាត់បានដាក់ជូនមកអ.វ.ត.ក។ ការវិភាគនេះបានរាប់បញ្ចូលនូវអ្នកដាក់ពាក្យបណ្តឹងធម្មតា និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើម-បណ្តឹងរដ្ឋប្បវេណីទាំងអស់ ទាំងក្នុងសំណុំរឿង០០១ និងសំណុំរឿង០០២ រហូតមកទល់បច្ចុប្បន្ននេះ។ ក្នុងចំណោមសូចនាករដ៏ច្រើនលើសលប់បំផុតនោះ គឺសំណើសុំមន្ទីរពេទ្យថែទាំសុខភាពផ្លូវចិត្ត ឬផ្លូវកាយបន្ថែមទៀត(១៨%) សំណើសុំវិធានការផ្នែកអប់រំ ដូចជា ការសាងសង់សាលារៀន និងការដាក់បញ្ចូលប្រវត្តិខ្មែរក្រហមក្នុងកម្មវិធីសិក្សា(១៦%) សំណើសុំការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមមូលដ្ឋាន(១៦%), សំណើសុំសំណងជាលក្ខណៈបុគ្គល ពិសេសការជួសជុលការបាត់បង់ទ្រព្យសម្បត្តិ(១២%) សំណើសុំស្វែងរកយុត្តិធម៌ (១១%) ក្នុងនោះរាប់បញ្ចូលទាំង ការជំនុំជម្រះដែលយុត្តិធម៌ និងលឿន និងការស៊ើបអង្កេតអំពីមូលហេតុ ដែលបណ្តាលឲ្យពួកខ្មែរក្រហមប្រព្រឹត្តឧក្រិដ្ឋកម្ម និងសំណើសុំឲ្យបង្កើតជាបូជនីយដ្ឋាន(៩%)។

ផ្អែកទៅលើចំណុចអាទិភាពនានា ដូចបានពណ៌នាដោយជនរងគ្រោះ អ្នកចូលរួមត្រូវបានអញ្ជើញឲ្យឆ្លុះបញ្ចាំងអំពីទំហំនៃសកម្មភាពអនុវត្តកន្លងមក ដែលបានឆ្លើយតបទៅនឹងផលប្រយោជន៍ទាំងនេះ។ បន្ថែមលើ

នេះទៀត អ្នកចូលរួមក៏ត្រូវបានអញ្ជើញឲ្យកំណត់នូវចន្លោះប្រហោងនៃការអនុវត្តសកម្មភាពនាពេលបច្ចុប្បន្ន ក៏ដូចជាមាគ៌ាសម្រាប់ការអភិវឌ្ឍបន្ថែមក្នុងវិស័យទាំងនេះ។

វិធាន ១២ *ស្ទួន*(២)នៃវិធានផ្ទៃក្នុងរបស់តុលាការប្រគល់ភារកិច្ចឲ្យអង្គភាពគាំពារជនរងគ្រោះ "ធ្វើការរៀបចំ និងអនុវត្តកម្មវិធី ព្រមទាំងវិធានការនានាដែលមិនពាក់ពន្ធ័នឹងបច្ចេកទេសច្បាប់ ដើម្បីផ្តល់ជាប្រយោជន៍ដល់ជនរងគ្រោះឲ្យកាន់តែទូលំទូលាយ"។ បទប្បញ្ញត្តិនេះ ដែលពឹងផ្អែកទៅលើធនធាន អនុញ្ញាតឲ្យអង្គភាពគាំពារជនរងគ្រោះកំណត់នូវចន្លោះប្រហោងក្នុងសេវាកម្មនានា ដែលបានផ្តល់ដល់ជនរងគ្រោះពីរបបខ្មែរក្រហម និងក្នុងករណីសមស្រប ដឹកនាំ, ជួយគាំទ្រ និងសម្របសម្រួលសកម្មភាពទំនាក់ទំនងរបស់សង្គមស៊ីវិល។

លោក រោង ឈុង ប្រធានអង្គភាពគាំពារជនរងគ្រោះបានអះអាងថា "ពេញចិត្តយ៉ាងខ្លាំង" នឹងទិន្នន័យក្នុងបទឧទ្ទេសនាមស្តីពីតម្រូវការ និងចំណូលចិត្តចង់បានរបស់ជនរងគ្រោះ ដែលលោកចាត់ទុកថា ជា "ចំណុចចាប់ផ្តើមដ៏សំខាន់មួយសម្រាប់ការអនុវត្តផ្នែកនេះនៃអាណត្តិរបស់អង្គភាព"។ លោកបានសង្កត់ធ្ងន់ថា "អង្គភាពគាំពារជនរងគ្រោះមិនប្រាថ្នាអនុវត្តសកម្មភាពដែលជាន់គ្នា ឬត្រួតលើកិច្ចខិតខំប្រឹងប្រែងដ៏ធំធេង ដែលបានអនុវត្តកន្លងមកហើយ ក្នុងការជួយគាំទ្រឲ្យកាន់តែទូលំទូលាយដល់ជនរងគ្រោះនោះទេ ប៉ុន្តែត្រូវធ្វើដំណើរទៅមុខជាមួយនឹងដៃគូទាំងអស់ ដើម្បីកសាងរួមគ្នា ដោយកិច្ចសហការជាមួយនឹងអ្នកពាក់ព័ន្ធទាំងអស់ ដែលទាំងអស់គ្នាឯកភាពថា នឹងត្រូវអនុវត្តសកម្មភាពបន្ថែមទៀត"។

- - -